# លិខិតដាក់ពេលណាត់ជួបសម្រាប់ទាយកដ្ឋានឧបត្ថម្ភកុមារ (DCS)
# ការកំណត់មើលមូលហេតុត្រឹមត្រូវ
## Appointment Letter for Division of Child Support (DCS) Good Cause Determination

កាលបរិច្ឆេទ ៖ លេខអតិថិជន ៖

ជូនចំពោះ ៖

សូមជម្រាបមកដល់ សូមជ្រាប,

អ្នកបានស្នើសុំការអនុគ្រោះផ្នែកលើមូលហេតុត្រឹមត្រូវ (Good Cause) ហើយបានប្រាប់ការិយាល័យសេវាសគមន៍ (Community Services Office, CSO) ប្រចាំមូលដ្ឋានរបស់អ្នកថា អ្នកមិនអាចជួយទាយកដ្ឋានឧបត្ថម្ភកុមារ (Division of Child Support, DCS) ក្នុងការទារប្រាក់ឧបត្ថម្ភកូន និង/ឬ ប្រាក់ឧបត្ថម្ភវេជ្ជសាស្ត្របានទេ។ DCS ផ្តល់សេវាទារប្រាក់ឧបត្ថម នៅពេលដែលអ្នកទទួលបាន TANF។ សេវាទាំងនេះអាចរួមបញ្ចូល ការបង្កើតអោយមានភាពជាឪពុករបស់ DCS ចុះ និង ទារអោយមានដីការឧបត្ថម, ទាមទារអោយ អាណាព្យាបាលម្ខាងទៀតអោយមាន កាតព្វកិច្ចក្នុងការផ្តល់ការធានារ៉ាប់រងសុខភាព និង ជួយចេញចំណែកនៃការចំណាយលើវេជ្ជសាស្ត្រដែលមិនស្ថិតនៅក្នុងការធានា សំរាប់ កូនៗរបស់អ្នក។

ខ្ញុំបានដាក់ពេលណាត់ជួបខាងក្រោមនេះ ដើម្បីពិគ្រោះជាមួយអ្នកអំពីការស្នើសុំការអនុគ្រោះផ្អែកលើមូលហេតុត្រឹមត្រូវរបស់អ្នក ដើម្បីបញ្ឈប់វិធានការទារ ប្រាក់ឧបត្ថម្ភកូន និង ប្រាក់ឧបត្ថម្ភវេជ្ជសាស្ត្រណាមួយ។

| ______________________ | ______________ | ______________ |
|---|---|---|
| អាសយដ្ឋាន | កាលបរិច្ឆេទ | ពេលម៉ោង |

បើអ្នកមិនអាចមកជួបខ្ញុំបានទេ, សូមទូរស័ព្ទមកខ្ញុំតាមលេខ ______________ ឲ្យទាន់ ______________។ **បើអ្នកមិនទូរស័ព្ទមកខ្ញុំ ឬមិនមកជួបខ្ញុំទៅតាមពេលណាត់ជួបទេ, ខ្ញុំអាចនឹងបដិសេធមិនផ្តល់ការអនុគ្រោះផ្អែកលើមូលហេតុត្រឹមត្រូវរបស់អ្នក។**

ខ្ញុំនឹងអនុម័តការស្នើសុំការអនុគ្រោះផ្អែកលើមូលហេតុត្រឹមត្រូវនេះ ប្រសិនបើវាត្រូវបានកំណត់ឃើញថា ៖

- អ្នកភ័យខ្លាចថា រូបអ្នក ឬកូន(ៗ)ដែលស្ថិតក្នុងបន្ទុកបីបាច់របស់អ្នកនឹងត្រូវប្រឈមនឹងគ្រោះថ្នាក់ធ្ងន់ធ្ងរលើផ្លូវកាយ ឬផ្លូវអារម្មណ៍។
- កូនរបស់អ្នកបានកើតមកដោយសារអំពើចាប់រំលោភ ឬអំពើស្នន់។
- អ្នកបានចាប់ផ្តើមអនុវត្តនីតិវិធីដាក់កូនគេចិញ្ចឹមជាកូនចិញ្ចឹម, ឬអ្នកកំពុងតែប្រឹក្សាយោបល់(រហូតដល់បីខែរ)ជាមួយទីភ្នាក់ងារចិញ្ចឹមកុមារ

ដើម្បីស្វែងលទ្ធភាពអំពីការដាក់កូនឲ្យគេចិញ្ចឹមជាកូនចិញ្ចឹម។

នៅក្នុងពេលណាត់ជួប, អ្នកអាចសរសេរលិខិតថ្លែងការណ៍ចុះហត្ថលេខាណាមួយច្បាប់ ដែលពណ៌នាអំពីទុក្ខកង្វល់ និងការភ័យខ្លាចនានារបស់អ្នក។ អ្នកក៏អាចនាំយកព័ត៌មានដទៃៗទៀតមកជាមួយអ្នកផងដែរ ដើម្បីជួយទ្រទ្រង់ការស្នើសុំរបស់អ្នក, បើមាន។ ឧទាហរណ៍នៃព័ត៌មានទាំងនេះអាចរួមមានដូចជា ៖

- របាយការណ៍ប៉ូលិស(នានា);
- របាយការណ៍វេជ្ជសាស្ត្រ(នានា);
- របាយការណ៍តុលាការ(នានា);
- ដីកាទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ;
- លិខិតថ្លែងការណ៍ពីគ្រូប្រដៅសាសនា, មិត្តភក្តិ, សាច់ញាតិ, អ្នកជិតខាង, មិត្តរួមការងារ ដែលពណ៌នាអំពីគ្រោះថ្នាក់ដែលអ្នកប្រឈម;
- សំបុត្រពីទីភ្នាក់ងារផ្តល់ជម្រកជូនជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ; ឬ
- សំបុត្រពីអ្នកផ្តល់ឱវាទផ្នែកអំពើហិង្សាក្នុងគ្រួសារ(នានា)។

**តើនឹងមានអ្វីកើតឡើងនៅក្នុងជំនួបនៃការណាត់ជួបនេះ?**

- អ្នកនឹងត្រូវបានផ្តល់ឱកាសឲ្យនិយាយពន្យល់អំពីមូលហេតុនានា ដែលធ្វើឲ្យអ្នកភ័យខ្លាចថា ការទារប្រាក់ឧបត្ថម្ភកូន និង/ឬប្រាក់ឧបត្ថម្ភវេជ្ជសាស្ត្រនេះ អាចនឹងនាំមកនូវគ្រោះថ្នាក់ដល់រូបអ្នក ឬកូន(ៗ)របស់អ្នក។
- យើងអាចពិគ្រោះគ្នាអំពីជំនួយផ្សេងៗ ដែលអ្នកអាចនឹងត្រូវការ ដើម្បីជួយអ្នកឲ្យអាចរស់នៅដោយសុវត្ថិភាព។

**តើនឹងមានអ្វីកើតឡើង ប្រសិនបើអ្នកមិនផ្តល់លិខិតថ្លែងការណ៍ចុះហត្ថលេខា ឬព័ត៌មានដទៃៗទៀត ដើម្បីបង្ហាញអំពីមូលហេតុដែលថា ការទារប្រាក់ ឧបត្ថម្ភកូន និង/ឬប្រាក់ឧបត្ថម្ភវេជ្ជសាស្ត្រ អាចនាំឲ្យរូបអ្នក ឬកូន(ៗ)របស់អ្នកប្រឈមនឹងថ្នាក់?**

- ការស្នើសុំរបស់អ្នកអាចត្រូវបានបដិសេធ ប្រសិនបើយើងរកមិនឃើញថា ហេតុផល(នានា)ដែលបានផ្តល់ មានលក្ខណសម្បត្តិស្របតាមលក្ខខណ្ឌតម្រូវទាំងប៉ុន្មានសម្រាប់ការអនុម័តិការអនុគ្រោះផ្អែកលើមូលហេតុត្រឹមត្រូវទេនោះ ហើយ
- សំណុំរឿងរបស់អ្នកនឹងត្រូវបញ្ជូនទៅ DCS ដើម្បីបើកសំណុំរឿងក្តីឧបត្ថមកូន សំរាប់សេវាទាមទារឧបត្ថមទាំងមូល។
- អានទឹងមានភ្នាក់ងារគាំពារអំពើហិង្សាក្នុងគ្រួសារនៅតាមការិយាល័យ CSO ប្រចាំមូលដ្ឋានរបស់អ្នកក្នុងសហគមន៍របស់អ្នក ដែលអាចនឹងរំលែក ពេលមកប្រជុំជាមួយអ្នកនៅក្នុងជំនួបនេះ។ សូមទាក់ទងការិយាល័យ CSO ប្រចាំមូលដ្ឋានរបស់អ្នក ដើម្បីស្នើសុំព័ត៌មានពិស្តារបន្ថែម។

**ចុះបើអ្នកមិនយល់ស្របជាមួយនឹងសេចក្តីសម្រេចរបស់យើង?**

1. អ្នកអាចទូរស័ព្ទទាក់ទងទៅការិយ័យ CSO របស់អ្នក ឬសរសេរលិខិតលាយលក្ខណ៍អក្សរទៅ Office of Administrative Hearings, PO Box 42489, Olympia WA 98504-2489 ឲ្យទាន់ក្នុងរយៈពេល 90 ថ្ងៃ ដើម្បីស្នើសុំសវនការ។ បើអ្នកស្នើសុំសវនាការ, នោះ DCS នឹងមិនចាប់ផ្តើម ធ្វើការលើសំណុំរឿងរបស់អ្នកទេ រហូតទាល់តែសេចក្តីសម្រេចនៃអង្គសវនាការនេះបានឈានដល់ទីអវសាន។ អ្នកអាចរើសរកមេធាវី ឬជនណាម្នាក់ ឲ្យធ្វើជាតំណាងរបស់អ្នកនៅក្នុងសវនាការ ឬអ្នកអាចធ្វើជាតំណាងឲ្យខ្លួនឯងក៏បាន។
2. ដកការស្នើសុំរបស់អ្នកចេញពីជំនួយ TANF។ តែទោះជាយ៉ាងណាក្តី, DCS អាចនឹងធ្វើការលើសំណុំរឿងរបស់អ្នកក្នុងខណៈ ពេលអ្នកកំពុងទទួលជំនួយ TANF។
3. បន្តទទួលជំនួយ តែមិនចូលរួមក្នុងសកម្មភាពអនុវត្តន៍វិធានការទារប្រាក់ឧបត្ថម្ភ។ តែទោះយ៉ាងណាក្តី, បើអ្នកមិនចូលរួមក្នុងសកម្មភាពអនុវត្តន៍វិធានការ ទារប្រាក់ឧបត្ថម្ភទេ, នោះ DCS នឹងបន្តធ្វើការលើសំណុំរឿងរបស់អ្នក ហើយជំនួយប្រាក់សុទ្ធរបស់អ្នកអាចនឹងត្រូវកាត់បន្ថយ 25% ប្រសិនបើការស្នើ សុំការអនុគ្រោះផ្អែកលើមូលហេតុត្រឹមត្រូវរបស់អ្នកត្រូវបានបដិសេធ។ អ្នកអាចរើសរកមេធាវី ឬជនណាម្នាក់ឲ្យធ្វើជាតំណាងរបស់អ្នកនៅក្នុងសវនាការ ឬអ្នកអាចធ្វើជាតំណាងឲ្យខ្លួនឯងក៏បាន។

**តើអ្នកអាចទទួលដំបូន្មានផ្នែកច្បាប់ ឬការតំណាងដោយអ្នកច្បាប់បានទេ?**

អ្នកអាចទូរស័ព្ទទាក់ទងទៅបណ្តាញសេវាច្បាប់ទូទាំងរដ្ឋ តាមលេខ 1-888-201-1014 ដើម្បីស្វែងយល់ព័ត៌មានផ្នែកច្បាប់។